ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ: ...០០៤ សជណ.../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី...១៣... ខែ...ធ្នូ... ឆ្នាំ២០១៤

**គោរពជូន**
**ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារវិមជ្ឈការ**
**និងវិសហមជ្ឈការនៃក្រសួង ស្ថាប័ន**

**កម្មវត្ថុ ៖** សេចក្តីណែនាំស្តីពីការកំណត់ប្រាក់បេសកកម្មនៅក្នុងប្រទេសក្នុងក្របខ័ណ្ឌផអ៣ទី២នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

**យោង ៖**
- អនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- លិខិតលេខ ៣៤២ អ.គ.គ.ក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីគោលការណ៍អនុវត្តអនុក្រឹត្យលេខ ២១៦ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស ។
- លិខិតចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់ធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីគោលការណ៍ក្នុងការធ្វើសុខដុមនីយកម្មនៃការអនុវត្តប្រាក់បេសកកម្មក្នុងស្រុក ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវមេត្តាជ្រាបថា រាជរដ្ឋាភិបាលបានអនុម័ត និងដាក់ឱ្យប្រើប្រាស់នូវអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។ កន្លងមកការរៀបចំផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ លើការកំណត់ប្រាក់ឧបត្ថម្ភសម្រាប់បេសកកម្ម គឺអនុវត្តទៅតាមអនុក្រឹត្យលេខ១០អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៤ ស្តីពីការកំណត់របបបេសកកម្មក្នុងនិងក្រៅប្រទេស និងសេចក្តីណែនាំលេខ៨១៩ សជណ/គ.ជ.អ.ប ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់លេខាធិការដ្ឋាន គ.ជ.អ.ប ។ ដោយថវិកាសម្រាប់បេសកម្មនេះគាំទ្រស្ទើរទាំងស្រុងពីដៃគូអភិវឌ្ឍន៍ អាស្រ័យហេតុនេះលេខាធិការដ្ឋានចាំបាច់សម្របសម្រួលឱ្យមានការឯកភាពពីដៃគូអភិវឌ្ឍន៍នានាផងដែរ ។ យោងតាម ស្មារតីនៃអនុក្រឹត្យលេខ២១៦ និងការឯកភាពពីដៃគូអភិវឌ្ឍន៍ លេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការណែនាំអំពី នីតិវិធីសម្រាប់ការប្រើប្រាស់ប្រាក់បេសកកម្ម និងថ្លៃធ្វើដំណើរក្នុងគោលដៅដើម្បីកំណត់ប្រាក់សម្រាប់ការបំពេញ បេសកកម្មរបស់ថ្នាក់ដឹកនាំមន្ត្រីរាជការសាធារណៈ ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាដែលបំរើការងារនៅក្នុង ក្របខ័ណ្ឌផអ៣ទី២នៃកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដូចមាន រៀបរាប់ខាងក្រោម ៖

**១. គោលការណ៍សម្រាប់ការអនុវត្តរបបប្រាក់បេសកកម្ម**

ដើម្បីធានាការប្រើប្រាស់ថវិកាសម្រាប់បេសកកម្មប្រកបដោយការសន្សំសំចៃ និងមានប្រសិទ្ធភាពខ្ពស់ការប្រើប្រាស់ថវិកាបេសកកម្ម ក្នុងក្របខ័ណ្ឌនៃថវិកាគាំទ្រកិច្ចប្រតិបត្តិការពីកម្មវិធីកំណែទម្រង់នៃការអភិវឌ្ឍ

តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមគោលការណ៍មួយចំនួនដូចខាងក្រោម ៖

- របបប្រាក់បេសកកម្មសម្រាប់បេសកកម្មស្នាក់នៅពេលយប់ និងបេសកកម្មមិនស្នាក់នៅពេលយប់ ត្រូវអនុវត្តស្មើគ្នាក្នុងអត្រារួមមួយសម្រាប់ថ្នាក់ដឹកនាំ មន្ត្រីរាជការសាធារណៈ ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាគ្រប់មុខតំណែងទាំងអស់ ។
- សេចក្តីណែនាំនេះមានប្រសិទ្ធភាពសម្រាប់លិខិតបេសកកម្មនានាដែលត្រូវអនុវត្តចាប់ពីថ្ងៃទី**១៥ ខែមករា ឆ្នាំ២០១៥**តទៅ។
- បេសកកម្មទាំងអស់ត្រូវមានការអនុញ្ញាតពីថ្នាក់ដឹកនាំរបស់ក្រសួង ស្ថាប័ន។
- ប្រាក់បេសកកម្មត្រូវកម្រិតខ្ពស់បំផុតត្រឹម១០ថ្ងៃសម្រាប់មន្ត្រីម្នាក់ៗក្នុងមួយខែ។
- ក្រសួង ស្ថាប័នត្រូវទទួលខុសត្រូវ និងធានាថា រាល់ការចាត់តាំងឱ្យមានបេសកកម្មនីមួយៗត្រូវមានមន្ត្រីដែលជាអ្នកចុះបំពេញបេសកកម្មពិតប្រាកដ។
- កំណត់ចំនួនថ្ងៃនៃការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា ឬកិច្ចប្រជុំផ្សេងៗឱ្យបានសមស្របទៅតាមទំហំការងារជាក់ស្តែង និងខិតខំដាក់បញ្ចូលគ្នា ឬរៀបចំឡើងក្នុងពេលតែមួយ និងនៅទីតាំងតែមួយនូវសកម្មភាពនានាដែលមានលក្ខណៈស្រដៀងគ្នា ព្រមទាំងខិតខំប្រើប្រាស់ឱ្យអស់លទ្ធភាពនូវអគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីរៀបចំកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលនានា។
- ការចំណាយថវិកាសម្រាប់ប្រាក់បេសកកម្មនៃសកម្មភាពចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ តាមដាន និងផ្តល់ការគាំទ្របច្ចេកទេស ត្រូវកំណត់ក្នុងក្របខ័ណ្ឌថវិកាសរុបប្រចាំឆ្នាំដែលបានអនុម័ត។ ចំនួនថវិកាសរុបនេះអាចកែសម្រួលបាន តែមិនឱ្យលើសពី១៥%នៃថវិកាដែលបានអនុម័ត ហើយត្រូវមានការឯកភាពពីលេខាធិការដ្ឋាន គ.ជ.អ.ប។
- ចំពោះ ចំណាយសម្រាប់ថ្លៃធ្វើដំណើររបស់ក្រសួង ស្ថាប័នដែលអនុវត្តការងារក្នុងក្របខ័ណ្ឌនៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវអនុវត្តតាមអត្រាចំណាយដែលបានរៀបចំដោយលេខាធិការដ្ឋាន គ.ជ.អ.ប។
- ការទូទាត់ថ្លៃបេសកកម្មអាចអនុវត្តបានសម្រាប់បេសកកម្មណា ដែលមានការអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ឬអ្នកទទួលបានការផ្ទេរសិទ្ធិ និងត្រូវមានរបាយការណ៍អំពីលទ្ធផលនៃបេសកកម្មនោះដែលបានទទួលការពិនិត្យ និងឯកភាពពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ឬអ្នកទទួលបានការផ្ទេរសិទ្ធិ។
- ជារៀងរាល់ខែ អង្គភាពហិរញ្ញវត្ថុរបស់ក្រសួង ស្ថាប័នត្រូវរៀបចំ និងដាក់ជូនថ្នាក់ដឹកនាំរបស់ខ្លួននូវរបាយការណ៍ស្តីពីការអនុវត្តប្រាក់បេសកកម្មសរុបក្នុងខែនីមួយៗ ធៀបនឹងថវិកាបេសកកម្មប្រចាំខែដែលបានគ្រោងទុកក្នុងចំណាយប្រតិបត្តិការទូទៅ ដើម្បីធានាដល់ការប្រើប្រាស់ថវិកាសម្រាប់បេសកកម្មក្នុងក្របខ័ណ្ឌថវិកាសរុបប្រចាំឆ្នាំដែលបានអនុម័ត។
- អង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី និងអង្គភាពរដ្ឋបាលនិងហិរញ្ញវត្ថុនៃលេខាធិការដ្ឋាន គ.ជ.អ.ប នឹងចុះតាមដានការអនុវត្តប្រាក់បេសកកម្មនៅតាមស្ថាប័នអនុវត្តនីមួយៗ។

**២. ការអនុវត្តរបបប្រាក់បេសកកម្ម**

**ក. សម្រាប់បេសកកម្មស្នាក់នៅពេលយប់**

បេសកកម្មស្នាក់នៅពេលយប់ សំដៅលើបេសកកម្មសម្រាប់អនុវត្តសកម្មភាពនានាដូចជា ការចុះមូលដ្ឋាន

ដើម្បីតាមដាននិងផ្តល់ការគាំទ្របច្ចេកទេស ការរៀបចំ ឬការចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល ដែលមានចម្ងាយលើសពី៤០គ.ម ចេញពីរាជធានីភ្នំពេញដែលសាមីខ្លួន បំពេញមុខតំណែងជាប្រចាំ និងស្ថិតនៅក្នុង ទីតាំងភូមិសាស្ត្រដែលតម្រូវឱ្យមានការស្នាក់នៅពេលយប់ជាចាំបាច់។

ការផ្តល់ប្រាក់បេសកកម្មសម្រាប់បេសកកម្មស្នាក់នៅពេលយប់ត្រូវអនុវត្តដូចខាងក្រោម ៖

- ការបំពេញបេសកកម្មស្នាក់នៅពេលយប់របស់មន្ត្រី បុគ្គលិកនៃក្រសួង ស្ថាប័ន នឹងត្រូវបានផ្តល់ជូនប្រាក់ហោប៉ៅ ប្រាក់ហូបចុក និងប្រាក់ស្នាក់នៅក្នុងអត្រាស្មើគ្នាដែលមានទឹកប្រាក់សរុបចំនួន៣៤ដុល្លារក្នុងមួយយប់។
- នៅថ្ងៃត្រឡប់មកពីបំពេញបេសកកម្មវិញ នឹងត្រូវបានផ្តល់ជូនប្រាក់ហោប៉ៅ និងប្រាក់ហូបចុកតែប៉ុណ្ណោះដែលមានទឹកប្រាក់សរុបចំនួន១៤ដុល្លារបន្ថែមទៀត។

**៥. សម្រាប់បេសកកម្មមិនស្នាក់នៅពេលយប់**

បេសកកម្មមិនស្នាក់នៅពេលយប់ សំដៅលើបេសកកម្មសម្រាប់ការអនុវត្តសកម្មភាពនានាពេញមួយថ្ងៃ ដូចជា ការចុះមូលដ្ឋាន ដើម្បីតាមដាននិងផ្តល់ការគាំទ្របច្ចេកទេស ការរៀបចំ ឬការចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលនៅតាមបណ្តាខេត្ត ក្រុង ស្រុក និងឃុំ សង្កាត់ចេញពីរង្វង់រាជធានីភ្នំពេញដែលសាមីខ្លួនបំពេញមុខតំណែងជាប្រចាំ។

ការបំពេញបេសកកម្មមិនស្នាក់នៅពេលយប់របស់មន្ត្រី បុគ្គលិកនៃក្រសួង ស្ថាប័ន នឹងត្រូវបានផ្តល់ជូនប្រាក់ហោប៉ៅ និងប្រាក់ហូបចុកតែប៉ុណ្ណោះដែលមានទឹកប្រាក់សរុបចំនួន១៤ដុល្លារ។

នៅពេលមានការណែនាំបន្ថែមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអំពីវិធាន និងនីតិវិធីសម្រាប់ការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស ដូចមានចែងក្នុងមាត្រា២៣នៃអនុក្រឹត្យលេខ២១៦ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើការណែនាំបន្ថែមអំពីការអនុវត្តប្រាក់បេសកកម្មនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមស្មើឯកឧត្តម លោកជំទាវ មេត្តាចាត់ចែង និងអនុវត្តតាមស្មារតីនៃលិខិតនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម លោកជំទាវ មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ៕

**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធាន**
**លេខាធិការដ្ឋាន គ.ជ.អ.ប**

សក់_សេដ្ឋា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខ: ..០០៣៦៣៩/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី.១៣ ខែ.មករា. ឆ្នាំ២០១៥

**សូមជម្រាបជូន**

**ឯកឧត្តមអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ ៖** សេចក្តីណែនាំស្តីពីការកំណត់ប្រាក់បេសកកម្មនៅក្នុងប្រទេសសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងក្របខ័ណ្ឌផអ៣ទី២នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

**យោង ៖**
- អនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។
- លិខិតលេខ ៣៤២ អ.គ.គ.ក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីគោលការណ៍អនុវត្តអនុក្រឹត្យលេខ ២១៦ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស ។
- លិខិតចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់ធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីគោលការណ៍ក្នុងការធ្វើសុខដុមនីយកម្មនៃការអនុវត្តប្រាក់បេសកកម្មក្នុងស្រុក ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា រាជរដ្ឋាភិបាលបានអនុម័ត និងដាក់ឱ្យប្រើប្រាស់នូវអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។ កន្លងមកការរៀបចំផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិលើការកំណត់ប្រាក់ឧបត្ថម្ភសម្រាប់បេសកកម្ម គឺអនុវត្តទៅតាមអនុក្រឹត្យលេខ១០អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៤ ស្តីពីការកំណត់របបបេសកកម្មក្នុងនិងក្រៅប្រទេស និងសេចក្តីណែនាំលេខ៨១៩ សជណ/គ.ជ.អ.ប ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ របស់លេខាធិការដ្ឋាន គ.ជ.អ.ប ។ ដោយថវិកាសម្រាប់បេសកម្មនេះគាំទ្រស្ទើរទាំងស្រុងពីដៃគូអភិវឌ្ឍន៍ អាស្រ័យហេតុនេះ លេខាធិការដ្ឋានចាំបាច់សម្របសម្រួលឱ្យមានការឯកភាពពីដៃគូអភិវឌ្ឍន៍នានាផងដែរ ។ យោងតាមស្មារតីនៃអនុក្រឹត្យលេខ២១៦ និងការឯកភាពពីដៃគូអភិវឌ្ឍន៍ លេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការណែនាំអំពីនីតិវិធីសម្រាប់ការប្រើប្រាស់ប្រាក់បេសកកម្ម និងថ្លៃធ្វើដំណើរក្នុងគោលដៅដើម្បីកំណត់ប្រាក់សម្រាប់ការបំពេញបេសកកម្មរបស់ថ្នាក់ដឹកនាំ មន្ត្រីរាជការសាធារណៈ ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាដែលបំរើការងារនៅក្នុងក្របខ័ណ្ឌផអ៣ទី២នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដូចមានរៀបរាប់ខាងក្រោម ៖

## ១. គោលការណ៍សម្រាប់ការអនុវត្តរបបប្រាក់បេសកកម្ម

ដើម្បីធានាការប្រើប្រាស់ថវិកាសម្រាប់បេសកកម្មប្រកបដោយការសន្សំសំចៃ និងមានប្រសិទ្ធភាពខ្ពស់ រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌត្រូវអនុវត្តតាមគោលការណ៍មួយចំនួនដូចខាងក្រោម ៖

- របបប្រាក់បេសកកម្មសម្រាប់បេសកកម្មស្នាក់នៅពេលយប់ និងបេសកកម្មមិនស្នាក់នៅពេលយប់

ត្រូវអនុវត្តស្មើគ្នាក្នុងអត្រារួមមួយសម្រាប់ថ្នាក់ដឹកនាំ មន្ត្រីរាជការសាធារណៈ ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យាគ្រប់មុខតំណែងទាំងអស់។

- សេចក្តីណែនាំនេះមានប្រសិទ្ធភាពសម្រាប់លិខិតបេសកកម្មនានាដែលត្រូវអនុវត្តចាប់ពីថ្ងៃទី**១៥ ខែមករា ឆ្នាំ២០១៥**តទៅ។
- បេសកកម្មទាំងអស់ត្រូវមានការអនុញ្ញាតពីថ្នាក់ដឹកនាំរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ។
- ប្រាក់បេសកកម្មត្រូវកម្រិតខ្ពស់បំផុតត្រឹម១០ថ្ងៃសម្រាប់មន្ត្រីម្នាក់ៗក្នុងមួយខែ។
- រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ត្រូវទទួលខុសត្រូវ និងធានាថា រាល់ការចាត់តាំងឱ្យមានបេសកកម្មនីមួយៗត្រូវមានមន្ត្រីដែលជាអ្នកចុះបំពេញបេសកកម្មពិតប្រាកដ។
- កំណត់ចំនួនថ្ងៃនៃការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា ឬកិច្ចប្រជុំផ្សេងៗឱ្យបានសមស្របទៅតាមទំហំការងារជាក់ស្តែង និងខិតខំដាក់បញ្ចូលគ្នា ឬរៀបចំឡើងក្នុងពេលតែមួយ និងនៅទីតាំងតែមួយនូវសកម្មភាពនានាដែលមានលក្ខណៈស្រដៀងគ្នា ព្រមទាំងខិតខំប្រើប្រាស់ឱ្យអស់លទ្ធភាពនូវអគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីរៀបចំកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាលនានា។
- ការចំណាយថវិកាសម្រាប់ប្រាក់បេសកកម្មនៃសកម្មភាពចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ តាមដាន និងផ្តល់ការគាំទ្របច្ចេកទេស ត្រូវកំណត់ក្នុងក្របខ័ណ្ឌថវិកាសរុបប្រចាំឆ្នាំដែលបានអនុម័ត។ ចំនួនថវិកាសរុបនេះអាចកែសម្រួលបាន តែមិនឱ្យលើសពី១៥%នៃថវិកាដែលបានអនុម័ត ហើយត្រូវមានការឯកភាពពីលេខាធិការដ្ឋាន គ.ជ.អ.ប។
- ចំពោះចំណាយសម្រាប់ថ្លៃធ្វើដំណើររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រាជធានី ខេត្ត ត្រូវរៀបចំអត្រានៃថ្លៃធ្វើដំណើរសម្រាប់ប្រើប្រាស់នៅក្នុងរាជធានី ខេត្តនីមួយៗ និងត្រូវផ្ញើឯកសារនេះមួយច្បាប់មកលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីទុកជាឯកសារយោង និងតាមដានការអនុវត្ត។
- ការទូទាត់ថ្លៃបេសកកម្មអាចអនុវត្តបានសម្រាប់បេសកកម្មណា ដែលមានការអនុញ្ញាតពីថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ឬអ្នកទទួលបានការផ្ទេរសិទ្ធិ និងត្រូវមានរបាយការណ៍អំពីលទ្ធផលនៃបេសកកម្មនោះដែលបានទទួលការពិនិត្យ និងឯកភាពពីថ្នាក់ដឹកនាំរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ឬអ្នកទទួលបានការផ្ទេរសិទ្ធិ។
- ជារៀងរាល់ខែ អង្គភាពហិរញ្ញវត្ថុរបស់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌត្រូវរៀបចំ និងដាក់ជូនថ្នាក់ដឹកនាំរបស់ខ្លួននូវរបាយការណ៍ស្តីពីការអនុវត្តប្រាក់បេសកកម្មសរុបក្នុងខែនីមួយៗ ធៀបនឹងថវិកាបេសកកម្មប្រចាំខែដែលបានគ្រោងទុកក្នុងចំណាយប្រតិបត្តិការទូទៅ ដើម្បីធានាដល់ការប្រើប្រាស់ថវិកាសម្រាប់បេសកកម្មក្នុងក្របខ័ណ្ឌថវិកាសរុបប្រចាំឆ្នាំដែលបានអនុម័ត។
- អង្គភាពគ្រប់គ្រងនិងគាំទ្រកម្មវិធី និងអង្គភាពរដ្ឋបាលនិងហិរញ្ញវត្ថុនៃលេខាធិការដ្ឋាន គ.ជ.អ.ប នឹងចុះតាមដានការអនុវត្តប្រាក់បេសកកម្មនៅតាមស្ថាប័នអនុវត្តនីមួយៗ។

## ២. ការអនុវត្តរបបប្រាក់បេសកកម្ម

### ក. សម្រាប់បេសកកម្មស្នាក់នៅពេលយប់

បេសកកម្មស្នាក់នៅពេលយប់ សំដៅលើបេសកកម្មសម្រាប់អនុវត្តសកម្មភាពនានាដូចជា ការចុះមូលដ្ឋាន

ដើម្បីតាមដាននិងផ្តល់ការគាំទ្របច្ចេកទេស ការរៀបចំ ឬការចូលរួមកិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្តុះបណ្តាល នៅក្នុង និងនៅក្រៅរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌដែលមានចម្ងាយលើសពី៤០គ.ម ចេញពីសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលសាមីខ្លួនបំពេញមុខតំណែងជាប្រចាំ និងស្ថិតនៅក្នុងទីតាំងភូមិសាស្ត្រ ឬល័ក្ខខ័ណ្ឌនានា ដែលតម្រូវឱ្យមានការស្នាក់នៅពេលយប់ជាចាំបាច់។ រដ្ឋបាលរាជធានី ខេត្តនីមួយៗត្រូវកំណត់ឱ្យបានជាក់លាក់ អំពីទីតាំងភូមិសាស្ត្រនានាដែលតម្រូវឱ្យមានការស្នាក់នៅពេលយប់ជាចាំបាច់ក្នុងការចុះបំពេញបេសកកម្មការងារ។

ការផ្តល់ប្រាក់បេសកកម្មសម្រាប់បេសកកម្មស្នាក់នៅពេលយប់ត្រូវអនុវត្តដូចខាងក្រោម ៖

- ការបំពេញបេសកកម្មស្នាក់នៅពេលយប់របស់មន្ត្រី បុគ្គលិកនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងត្រូវបានផ្តល់ជូនប្រាក់ហោប៉ៅ ប្រាក់ហូបចុក និងប្រាក់ស្នាក់នៅក្នុងអត្រាស្មើគ្នាដែលមានទឹកប្រាក់សរុបចំនួន៣៤ដុល្លារក្នុងមួយយប់។
- នៅថ្ងៃត្រឡប់មកពីបំពេញបេសកកម្មវិញ នឹងត្រូវបានផ្តល់ជូនប្រាក់ហោប៉ៅ និងប្រាក់ហូបចុកតែប៉ុណ្ណោះដែលមានទឹកប្រាក់សរុបចំនួន១៤ដុល្លារបន្ថែមទៀត។

**៩. សម្រាប់បេសកកម្មមិនស្នាក់នៅពេលយប់**

រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌត្រូវបន្តអនុវត្តរបបបេសកកម្មសម្រាប់បេសកកម្មមិនស្នាក់នៅពេលយប់ ជាបណ្តោះអាសន្នតាមស្មារតីនៃសេចក្តីណែនាំលេខ៨១៩សជណ/គ.ជ.អ.ប ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២។

នៅពេលមានការណែនាំបន្ថែមពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអំពីវិធាន និងនីតិវិធីសម្រាប់ការអនុវត្តប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេស ដូចមាន ចែងក្នុងមាត្រា២៣នៃអនុក្រឹត្យលេខ២១៦ លេខាធិការដ្ឋាន គ.ជ.អ.ប នឹងធ្វើការណែនាំបន្ថែមអំពីការអនុវត្តរបបបេសកកម្មនេះ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមស្មើឯកឧត្តមមេត្តាចាត់ចែង និងអនុវត្តតាមស្មារតីនៃលិខិតនេះឱ្យទទួលបានប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តមទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ៕

រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធាន
លេខាធិការដ្ឋាន គ.ជ.អ.ប

សក់_សេដ្ឋា